# របាយការណ៍ប្រចាំ ៩ខែ ឆ្នាំ ២០១៤ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម

## I. សេចក្តីផ្តើម

### ១_ ស្ថានភាពភូមិសាស្ត្រ ខេត្តកំពង់ចាម

ខេត្តកំពង់ចាម ស្ថិតនៅដែនដីភាគខាងកើតប្រទេសកម្ពុជា ដែលមានចម្ងាយ ១២៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ខេត្តក៏មានផ្លូវជាតិសំខាន់ៗឆ្លងកាត់ដូចជាៈ ផ្លូវជាតិលេខ 6A ផ្លូវជាតិលេខ 7 ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ធំ និងខេត្តក្រចេះ ខាងត្បូងជាប់ខេត្តព្រៃវែង ខេត្តកណ្តាល ខាងកើតជាប់ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ខាងលិចជាប់ខេត្តកំពង់ឆ្នាំង ។

បច្ចុប្បន្នខេត្តកំពង់ចាមចែកចេញជាស្រុក-ក្រុង ឃុំ-សង្កាត់ និងភូមិរដ្ឋបាល ដែលមានក្រុងចំនួន ០១ក្រុង មានសង្កាត់ ០៤សង្កាត់ និងស្រុកចំនួន ០៩ស្រុក មានឃុំចំនួន ១០៥ឃុំ ស្មើនឹង ៩១៦ភូមិ ។

ខេត្តកំពង់ចាម មានផ្ទៃដីសរុប ៤៥៤៨,០៩គ.ម² ហើយមានអំណោយផលធម្មជាតិយ៉ាងល្អប្រសើរដល់ដំណាំកសិកម្ម ដំណាំស្បៀង កសិឧស្សាហកម្មផងដែរ ។ ខេត្តកំពង់ចាម មានប្រជាពលរដ្ឋសរុប ១.០៧៥.២២០នាក់ ចំនួនគ្រួសារសរុប ២៣៦.៨៣៥គ្រួសារ ចំនួនស្ត្រីសរុប ៥៥២.២០៧នាក់ ដង់ស៊ីតេ ២៣៦នាក់/គ.ម² ប្រជាកសិករប្រកបមុខរបរកសិកម្មចំនួន ៨0% មុខរបរសិប្បកម្ម ០.៨% សេវាកម្ម ១៦% មុខរបរមិនច្បាស់លាស់(ចម្រុះ) ៣.២០% ។

### ២_ ស្ថានភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបង្កើតឡើងនៅឆ្នាំ ១៩៩៤ រហូតដល់សព្វថ្ងៃមានការិយាល័យ ២០ ហើយចែកចេញជា ១០ការិយាល័យថ្នាក់ខេត្ត និង ១០ការិយាល័យថ្នាក់ស្រុក-ក្រុង ដោយមានមន្ត្រីសរុបចំនួន ៧៣នាក់ ក្នុងនោះមានស្រីចំនួន ២១នាក់ ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ដឹកនាំដោយប្រធានមន្ទីរ ១រូប អនុប្រធានមន្ទីរ ០៨រូប និងប្រធាន-អនុប្រធានការិយាល័យមន្ទីរ និងថ្នាក់ស្រុកចំនួន ៦៤នាក់ ។

## II. សកម្មភាពតាមការិយាល័យនីមួយៗថ្នាក់ខេត្ត

### ១_ ការងាររដ្ឋបាល និងបុគ្គលិក

បច្ចុប្បន្នមន្ទីរមានបុគ្គលិកក្របខ័ណ្ឌសរុបចំនួន ៧៣នាក់/ស្ត្រី ២១នាក់ គ្រប់គ្រងដោយប្រធានមន្ទីរ ០១រូប ទទួលបន្ទុកក្តាប់រួម និងអនុប្រធានមន្ទីរចំនួន ០៨រូប ក្នុងនោះមានស្ត្រី ០១រូប ។

- ការិយាល័យទាំង ១០ មានបុគ្គលិកសរុប ៤៤នាក់/ស្ត្រីមាន ១២នាក់ ។
- ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង និងស្រុកមានបុគ្គលិកសរុបចំនួន ២៩នាក់/ស្ត្រីចំនួន ០៩នាក់។
- ធ្វើលិខិតចេញបានចំនួន ៤៤៧ច្បាប់ និងទទួលលិខិតចូលចំនួន ៥២៣ច្បាប់ ។
- បានរៀបចំបញ្ជីវត្តមានប្រចាំថ្ងៃ ចំពោះមន្ត្រីការិយាល័យថ្នាក់ខេត្ត ។
- ធ្វើរបាយការណ៍ប្រចាំ ០៩ខែ ជូនសាលាខេត្ត និងក្រសួងទៀងទាត់រៀងរាល់ប្រចាំខែ ។

### ២_ ការងារគណនេយ្យ និងហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណទានគិត (៛) | បណ្តាខែមុន | ចំណាយក្នុងខែ | ចំណាយបូកយោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ទិញ | 148,200,000 | 61,975,980 | 11,653,900 | 73,629,880 | 74,570,120 |
| ៦១ | សេវាខាងក្រៅ | 514,700,000 | 50,697,820 | 10,103,600 | 60,801,420 | 453,898,580 |
| ៦២ | សេវាខាងក្រៅផ្សេងៗ | 261,500,000 | 146,247,520 | 25,052,011 | 171,299,531 | 90,200,469 |
| ៦៤ | បន្ទុកបុគ្គលិក | 790,200,000 | 538,510,380 | 67,092,940 | 605,603,320 | 184,596,680 |
| **សរុប** | | **1,714,600,000** | **797,431,700** | **113,902,451** | **911,334,151** | |

**៣_ ការងារផែនការ និងស្ថិតិ**

- រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៥-២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ជាមួយការិយាល័យហិរញ្ញវត្ថុ ។
- ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីបង្គោលថ្នាក់ជាតិស្តីពី ការកសាង និងគ្រប់គ្រងផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ និងកម្មវិធីវិនិយោគ បីឆ្នាំរំកិលរបស់ខេត្តកំពង់ចាម ។
- រៀបចំតារាងវិភាគស្ថានភាពសម្រាប់មន្ទីរ នៅមន្ទីរផែនការខេត្ត ។
- ចូលរួមជួយធ្វើរបាយការណ៍មន្ទីរតាមការិយាល័យជូនខេត្ត និងក្រសួងជាមួយការិយាល័យរដ្ឋបាល ។

**អធិការកិច្ច**

- ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៤ គណៈប្រតិភូអាជ្ញាធរសវនកម្មជាតិដឹកនាំដោយលោកស្រី គួយ ឡាង ប្រធានគណៈប្រតិភូ ចុះធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងសម្បត្តិរដ្ឋ ការអនុលោមតាមបទប្បញ្ញាតិ និងកិច្ចប្រតិបត្តការការងារឆ្នាំ២០១៣ និងឆ្នាំពាក់ព័ន្ធ ។
- ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៤ គណៈប្រតិភូនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងអភិវឌ្ឍន៍ជនបទ ដឹកនាំដោយ លោក **ពេជ្រ សេដ្ឋា** ប្រធាននាយកដ្ឋាន ចុះត្រួតពិនិត្យឯកសារ និងសកម្មភាពដែលក្រុមការងារសវនកម្មមាន÷
  - **១-** ឯកសារនីតិវិធីរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលឆ្នាំ២០១៣-២០១៤ ។
  - **២-** ផែនការសកម្មភាពឆ្នាំ២០១៤ ។
  - **៣-** របាយការណ៍លទ្ធផលការងាររបាយការណ៍ហិរញ្ញវត្ថុ និងវិក្កយបត្រទូទាត់ថវិកាឆ្នាំ ២០១៣-២០១៤ ។
  - **៤-** តាមដានអនុសាសន៍សវនកម្មឆ្នាំ ២០១៣ ។
  - **៥-** ចុះពិនិត្យជាក់ស្តែងលើគម្រោងសាងសង់បង្គន់អនាម័យ និងអណ្តូងទឹកស្អាតដោយប្រើប្រាស់ថវិកាក្នុងឆ្នាំ ២០១៣-២០១៤ ។
- ថ្ងៃទី ២៣-២៧ ខែមិថុនា ឆ្នាំ២០១៤ គណៈប្រតិភូក្រសួងអភិវឌ្ឍន៍ជនបទ អគ្គាធិការ ដឹកនាំដោយ លោក សេង សុធា អគ្គាធិការរងក្រសួងអភិវឌ្ឍន៍ជនបទ ចុះផ្សព្វផ្សាយនីតិវិធី និងផែនការយុទ្ធសាស្ត្ររបស់អគ្គាធិការដ្ឋាន (ប្រើប្រាស់ថវិកាកម្មវិធី) នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។
- ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៤ គណៈប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចដឹកនាំដោយ លោក **ជាម ស៊ីថុនល** អគ្គនាយករងនៃអគ្គនាយកដ្ឋាន អធិការកិច្ចចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល-ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការបរិច្ឆេទឆ្នាំ ២០១៣ និងបណ្តាឆ្នាំពាក់ព័ន្ធនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។

- ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៤ គណៈប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដឹកនាំដោយលោក **សូ សុទ្ធី** ជាអនុប្រធានគណៈប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រងចំណូល-ចំណាយថវិការដ្ឋ (ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី) និងកាតព្វកិច្ចត្រូវបង់ចំណូលថវិការដ្ឋឆ្នាំ២០១៣ និងបណ្តាឆ្នាំពាក់ព័ន្ធ ។

**<u>កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ</u>**

- ប្រធាន-អនុប្រធានមន្ទីរ និងមន្ត្រីរាជការមួយចំនួនបានចូលរួមប្រជុំផ្សេងៗចំនួន ២០៦លើក ។

## III. សកម្មភាពតាមវិស័យ

### ១- <u>ការិយាល័យផ្លូវលំជនបទ</u>

- ការងារថែទាំផ្លូវជាលក្ខណៈខួបមានចំនួន ១៦ខ្សែ ប្រវែង ៦២.៤៤គ.ម និងសាងសង់លូគ្រប់ប្រភេទចំនួន ១៥កន្លែង សម្រេចបាន ១០០%។
- ការងារថែទាំជាលក្ខណៈប្រចាំចំនួន ០៣ខ្សែ ប្រវែង ៤៩.៥០០គ.ម សម្រេចបាន ១០០% ។

1. <u>ការងារអនុវត្តដោយគម្រោង កេតសាណា (KETSANA)</u>
   - ការងារជួសជុលផ្លូវលំជនបទចំនួន ១០ខ្សែ ប្រវែង ៥៣.៥៥គ.ម សម្រេចបាន ១០០% ។
2. <u>ការងារសាងសង់ផ្លូវក្រាលគ្រួសក្រហមក្នុងគម្រោង EFAP</u>
   - សាងសង់ផ្លូវក្រាលគ្រួសក្រហមចំនួន ០៣ខ្សែ មានប្រវែង ៦.៧គ.ម ស្ថិតនៅស្រុកព្រៃឈរ និងស្រុកចំការលើ លទ្ធផលសម្រេចបាន ១០០% ។
3. <u>ការងារសាងសង់ផ្លូវប្រភេទ DBST របស់គម្រោង ADB</u>
   - ការកែលម្អផ្លូវក្រាលគ្រួសក្រហមទៅជាផ្លូវកៅស៊ូ DBST ចំនួន ០១ខ្សែ ប្រវែង ១០គ.ម ស្ថិតនៅស្រុកស្ទឹងត្រង់ លទ្ធផលសម្រេចបាន ៨៥% ។
   - ការកែលម្អផ្លូវក្រាលគ្រួសក្រហមទៅជាផ្លូវកៅស៊ូប្រភេទ DBST ចំនួន ០១ខ្សែ ប្រវែង ១៧គ.ម ស្ថិតនៅស្រុកបាធាយ ខេត្តកំពង់ចាម សម្រេចបាន ៦៥% ។

### ២- <u>ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ</u>

1. <u>ការងារកេតសាណា</u>
   - ខួងអណ្តូងបានចំនួន ៤៨អណ្តូង ក្នុងឃុំព្រែកបាក់បានចំនួន ១១អណ្តូង ស្រុកស្ទឹងត្រង់, ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំបានចំនួន ៣១អណ្តូង, ឃុំបឹងព្រួល ស្រុកត្បូងឃ្មុំ បានចំនួន ០៦អណ្តូង ។
2. <u>ការងារតម្លើងស្នប់បានចំនួន ១១៧អណ្តូង</u>
   - តម្លើងស្នប់ក្នុងឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ បានចំនួន ១៧អណ្តូង, ឃុំប្រាំយ៉ាមចំនួន ១៩អណ្តូង, ឃុំទ្រាសចំនួន ០៨អណ្តូង ស្រុកស្រីសន្ធរ, ឃុំទួលស្នួលចំនួន ១៦អណ្តូង ក្នុងស្រុកក្រូចឆ្មារ, ឃុំពាមជីលាំង ចំនួន ៣១អណ្តូង ឃុំបឹងព្រួលចំនួន ១៥អណ្តូង និងឃុំជីរោទី១ ចំនួន ១១អណ្តូង ក្នុងស្រុកត្បូងឃ្មុំ ។
3. <u>ការងារបង្គន់អនាម័យ</u>

   សាងសង់បង្គន់អនាម័យជើងក្រោមដោយក្រុមហ៊ុនចំនួន ១២៩២បង្គន់ នៅស្រុកត្បូងឃ្មុំ ស្រុកស្ទឹងត្រង់ និងស្រុកស្រីសន្ធរ÷

   - ជីកដាក់លូដាក់ចានរួចនៅភូមិវិហារក្រោមបាន ១៣២បង្គន់ ភូមិម៉ាស៊ីនស្រូវ ១០៥បង្គន់ ភូមិបាតជីក្រោមចំនួន ១០៨បង្គន់, ភូមិស្ពានឈើ ៦៤បង្គន់, ភូមិបឹងកក់ ២៤បង្គន់, ភូមិទួលកំពតទី១ ៥៧បង្គន់, ភូមិទួលកំពតទី៣ ៩៤បង្គន់, ទួលកំពត ទី១ បានចំនួន ៥៧បង្គន់, ភូមិម៉ាស៊ីនស្រូវចំនួន ៤៥បង្គន់, ភូមិទួលកំពតទី៣ ចំនួន ៩៤បង្គន់ ក្នុងឃុំបឹងព្រួល ។

- ជីកដាក់លូ និងដាក់ចាន្ទូច នៅភូមិព្រៃកព្រះអង្គ ២២៥បង្គន់ និងភូមិព្រៃករលួសបាន ១៥០បង្គន់ ក្នុងឃុំព្រៃកបាក់ ស្រុកស្ទឹងត្រង់ ។
- ជីកដាក់លូ និងដាក់ចាន្ទូចនៅភូមិព្រៃកផ្តៅបាន ១២៤បង្គន់ ភូមិកំពង់ចន្លុះកើតចំនួន ១១២បង្គន់ ភូមិព្រៃកពាមចំនួន ៩បង្គន់ ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ និងភូមិជើងដីកបានចំនួន ៩៤បង្គន់ ស្រុកស្រីសន្ធរ។

a. <u>របាយការណ៍អណ្តូងលូ អណ្តូងស្នប់លិចលង់ដោយទឹកជំនន់ស្រុកកងមាស៖</u>

| | | | |
|---|---|---|---|
| - ឃុំរការគយមានអណ្តូងលូ | ២៧៩អណ្តូង | អណ្តូងស្នប់ | ០៣អណ្តូង |
| - ឃុំពាមជីកងមានអណ្តូងលូ | ១៤អណ្តូង | អណ្តូងស្នប់ | ០អណ្តូង |
| - ឃុំព្រែកក្របៅមានអណ្តូងលូ | ១៧៩អណ្តូង | អណ្តូងស្នប់ | ០អណ្តូង |
| - ឃុំសូគងមានអណ្តូងលូ | ១១៧អណ្តូង | អណ្តូងស្នប់ | ១៣៧អណ្តូង |
| - ឃុំរាយប៉ាយមានអណ្តូងលូ | ៣៥អណ្តូង | អណ្តូងស្នប់ | ០អណ្តូង |
| **សរុបអណ្តូងលូចំនួន** | **៨១៣អណ្តូង** | **អណ្តូងស្នប់** | **៤០អណ្តូង** |

b. <u>របាយការណ៍អណ្តូងលូ អណ្តូងស្នប់លិចលង់ដោយទឹកជំនន់ស្រុកស្ទឹងត្រង់៖</u>

| | | | |
|---|---|---|---|
| - ឃុំព្រែកបាក់មានអណ្តូងលូ | ១៧អណ្តូង | អណ្តូងស្នប់ | ០អណ្តូង |
| - ឃុំពាមកោះស្នាមានអណ្តូងលូ | ២៨អណ្តូង | អណ្តូងស្នប់ | ០អណ្តូង |
| - ឃុំព្រះអណ្តូងមានអណ្តូងលូ | ១៩អណ្តូង | អណ្តូងស្នប់ | ០៣អណ្តូង |
| - ឃុំខ្ពបតាងួនមានអណ្តូងលូ | ០៨អណ្តូង | អណ្តូងស្នប់ | ១៣ងណ្តូង |
| **សរុបអណ្តូងលូចំនួន** | **៧២អណ្តូង** | **អណ្តូងស្នប់** | **១៣អណ្តូង** |

c. <u>របាយការណ៍អណ្តូងលូ អណ្តូងស្នប់លិចលង់ដោយទឹកជំនន់ស្រុកកំពង់សៀម៖</u>

| | | | |
|---|---|---|---|
| - ឃុំហាន់ជ័យមានអណ្តូងលូ | ០២អណ្តូង | អណ្តូងស្នប់ | ០១អណ្តូង |
| - ឃុំគៀងជ្រៃមានអណ្តូងលូ | ០៦អណ្តូង | អណ្តូងស្នប់ | ០អណ្តូង |
| - ឃុំគគរមានអណ្តូងលូ | ៣៦១អណ្តូង | អណ្តូងស្នប់ | ១៧អណ្តូង |
| - ឃុំកោះសំរោងមានអណ្តូងលូ | ៦៦អណ្តូង | អណ្តូងស្នប់ | ១១អណ្តូង |
| - ឃុំកោះរការមានអណ្តូងលូ | ០អណ្តូង | អណ្តូងស្នប់ | ០៧អណ្តូង |
| - ឃុំកោះមិត្តមានអណ្តូងលូ | ១៨អណ្តូង | អណ្តូងស្នប់ | ០អណ្តូង |
| - ឃុំកោះទន្ទឹមមានអណ្តូងលូ | ០៣អណ្តូង | អណ្តូងស្នប់ | ០៥អណ្តូង |
| **សរុបអណ្តូងលូចំនួន** | **៤៥៦អណ្តូង** | **អណ្តូងស្នប់** | **៤១អណ្តូង** |

4. <u>ការងារសហការជាមួយអង្គការ ១០០១</u>

- ចុះកំណត់ទីតាំងសាងសង់ស្ថានីយ៍ផលិតទឹកស្អាតបានចំនួន ១៤ស្ថានីយ៍ ក្នុងស្រុកចំនួន ០៤÷

| | | |
|---|---|---|
| ១- ស្រុកកំពង់សៀម | បានចំនួន | ០៥ស្ថានីយ៍ |
| ២- ស្រុកកងមាស | បានចំនួន | ០៣ស្ថានីយ៍ |
| ៣- ស្រុកស្រីសន្ធរ | បានចំនួន | ០៣ស្ថានីយ៍ |
| ៤- ស្រុកកោះសូទិន | បានចំនួន | ០១ស្ថានីយ៍ |

5. <u>ការងារសាងសង់អាងត្រង់ទឹកភ្លៀង (៣៨ម$^{៣}$ ស្រុកត្បូងឃ្មុំ)ចំនួន ០៨អាង</u>

- នៅអនុវិទ្យាល័យកំពង់ឫស្សី ឃុំជីរោទិ៍១ ចំនួន ០១អាង ។
- នៅអនុវិទ្យាល័យទួលវិហារ ឃុំជីរោទិ៍២ ចំនួន ០១អាង ។

- នៅសាលាបឋមសិក្សាឈើទាល១ ឃុំពាមជីលាំង ចំនួន ០១អាង ។
- នៅអនុវិទ្យាល័យថ្មពេជ្រ ឃុំថ្មពេជ្រ ចំនួន ០១អាង ។
- នៅសាលាបឋមសិក្សាទួលស្នួល ឃុំទួលស្នួល ចំនួន ០១អាង ។

6. ការងារស្តារប្រឡាយអូររុន ប្រវែង ៨០០ម៉ែត្រ ( ១៣មx៨x៣ម )
   - នៅភូមិខ្សាច់ប្រឆេះលើឃុំក្រូចឆ្មារ ប្រវែង ៨០០ម៉ែត្រ ទទឹងបាតលើ ១៣មx៨មx៣មចំនួន១ខ្សែ។

៣ - ការងារថែទាំសុខភាពជនបទ

- ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលរៀបចំដោយនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ ។
- ថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១៤ ចូលរួមខួបលើកទី១០៣ នៃទិវានារីអន្តរជាតិ ០៨មីនា នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។
- ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៤ ចូលរួមសន្និបាតបូកសរុបឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។
- ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៤ ប្រជុំស្តីពីការរៀបចំផ្សព្វផ្សាយកម្មវិធីកំណែទម្រង់រដ្ឋបាល នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។
- ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៤ ចូលរួមអបអរសាទរខួបលើកទី១៥១ ទិវាពិភពលោកកាកបាទក្រហមអឌ្ឍចន្ទក្រហម ០៨ ឧសភា ក្រោមប្រធានបទ “ខ្ញុំ និងកាកបាទក្រម” នៅសាលាខេត្តកំពង់ចាម ។
- ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៤ ចូលរួមទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅសាលាក្រុងកំពង់ចាម ។
- ថ្ងៃទី ០២-០៣ ខែកក្កដា ឆ្នាំ២០១៤ ចុះត្រួតពិនិត្យ និងជំរុញអោយអ្នកស្ម័គ្រចិត្តភូមិសាងសង់បង្គន់តាមផ្ទះ ព្រមទាំងនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។
- បើកវគ្គបណ្តុះបណ្តាលស្តីពី CLTS ក្នុងឃុំតាប្រុក ចំនួនអ្នកចូលរួម ២១នាក់ / ស្រី ១៦នាក់ និងឃុំជយោ ចំនួនអ្នកចូលរួម ២២នាក់ / ស្រី ១៥នាក់ នៅស្រុកចំការលើ និងក្នុងឃុំក្រូចចំនួនអ្នកចូលរួម ២១នាក់ / ស្រី ១៦នាក់ ឃុំមៀន ចំនួនអ្នកចូលរួម ៤៤នាក់ / ស្រីចំនួន ២១នាក់ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៤ ប្រជុំបូកសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកំពង់ចាម ប្រចាំឆមាសទី១ និងលើកទិសដៅភារកិច្ចឆមាសទី២ ឆ្នាំ២០១៤ ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៤ ប្រជុំគណៈកម្មាធិការប្រយុទ្ធ និងជម្ងឺអេដស៍ខេត្ត ស្តីពីការពិនិត្យសកម្មភាពអនុវត្តគំនិតផ្តួចផ្តើមកម្ពុជា ៣.០ នៅស្រុកប្រតិបត្តិ ស្រុកកំពង់សៀម និងខេត្តកំពង់ចាម ។
- ក្នុងខែកញ្ញា ឆ្នាំ២០១៤ ស្រុកកំពង់សៀម ស្ថិតិបង្គន់ចាក់ទឹកចំនួន ៨៥៣១បង្គន់ ហើយបង្គន់លិចទឹកចំនួន ១៧១៥បង្គន់ និងចាក់ផេះចំនួន ១៥១បង្គន់ លិចទឹកអស់ ៩៣បង្គន់, ស្រុកស្ទឹងត្រង់ ស្ថិតិបង្គន់លិចទឹកចំនួន ១២០បង្គន់, ស្រុកកោះសូទិន ស្ថិតិបង្គន់លិចទឹកចំនួន ៥០០៩បង្គន់, ស្រុកជើងព្រៃ ស្ថិតិបង្គន់ចាក់ទឹកចំនួន ៦៦០៧បង្គន់, បង្គន់ចាក់ផេះចំនួន ៤១០បង្គន់, ស្រុកព្រៃឈរ ស្ថិតិបង្គន់ចាក់ទឹកចំនួន ១១,៨៦៨បង្គន់ លិចទឹកអស់ ១០បង្គន់ និងបង្គន់ចាក់ផេះចំនួន ៧១៣បង្គន់, ស្រុកចំការលើស្ថិតិបង្គន់ចាក់ទឹកចំនួន ១០៧០៥បង្គន់ និងបង្គន់ចាក់ផេះចំនួន ៤៨១៩បង្គន់, ក្រុងកំពង់ចាម ស្ថិតបង្គន់ចាក់ទឹកចំនួន ៧៦៤៨បង្គន់ លិចទឹកអស់ ៦០៣បង្គន់ និងបង្គន់ចាក់ផេះ ចំនួន ៨១២៤បង្គន់, ស្រុកស្រីសន្ធរ ស្ថិតិបង្គន់ចាក់ទឹកចំនួន ៩៣០០០បង្គន់ លិចទឹកអស់ ៩៧៩បង្គន់ និងបង្គន់ចាក់ផេះចំនួន ៦៩៩បង្គន់, ស្រុកកងមាស ស្ថិតិបង្គន់ចាក់ទឹកចំនួន ៨២២៨បង្គន់ លិចទឹកអស់ ១៤៦១បង្គន់ និងបង្គន់ចាក់ផេះ ចំនួន ២២បង្គន់, ស្រុកបាធាយ ស្ថិតិបង្គន់ចាក់ទឹកចំនួន ៨១០៨បង្គន់ លិចទឹកអស់ ៩៨៩៧បង្គន់ និងបង្គន់ចាក់ផេះចំនួន ១៤៩៣៨បង្គន់ ។
- ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៤ ចូលរួមប្រជុំក្នុងគោលបំណងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក លើការអនុវត្តន៍គម្រោងលើកកម្ពស់សុខភាពអនាម័យជនបទ ។

## ៤- ការងារអភិវឌ្ឍន៍សហគមន៍ជនបទ

- ថ្ងៃទី ០៩-១០ ខែធ្នូ ឆ្នាំ២០១៣ បូកសរុបការងារអនាម័យបំណាច់ឆ្នាំ២០១៤ នៅសណ្ឋាគារភ្នំប្រុស ។
- ចុះវាយតម្លៃភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលបានចំនួន ០៦លើក ស្ថិតនៅស្រុកជើងព្រៃ ស្រុកព្រៃឈរ ខេត្តកំពង់ចាម និងស្រុកត្បូងឃ្មុំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។
- ចូលរួមប្រកាសទទួលស្គាល់ភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលបានចំនួន ០២លើក នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម និងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។
- រៀបចំបង្កើត គ.អ.ភ. បាន ០៩ភូមិ សមាជិកសរុប ៦៦នាក់ (ស្រី ២០នាក់) ក្នុងឃុំថ្មពួន ស្រុកព្រៃឈរ ។
- ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៤ បូកសរុបការងារឆ្នាំកន្លង ដើម្បីអនុវត្តន៍សម្រាប់ឆ្នាំ២០១៤ បន្តរបស់កម្មវិធីអង្គការ SNU នៅសណ្ឋាគារភ្នំប្រុស ។
- ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៤ សិក្ខាសាលារៀបចំផែនការថ្នាក់ស្រុកឆ្នាំ២០១៤ ស្តីពីការលើកកម្ពស់អនាម័យជនបទ នៅស្រុកសាលាស្រុកកំពង់សៀម ។
- ថ្ងៃទី ១៧-២១ ខែកុម្ភៈ ឆ្នាំ២០១៤ គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ហិរញ្ញប្បទានបន្ថែម សិក្ខាសាលាស្តីពី ការបណ្តុះបណ្តាលគ្រូបង្គោល និងរៀបចំផែនការបណ្តុះបណ្តាលសម្រាប់អង្គការដៃគូ និងមន្ទីរពាក់ព័ន្ធ ។
- ថ្ងៃទី ០៥-០៦ ខែមីនា ឆ្នាំ២០១៤ ចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពីការផ្លាស់ប្តូរទម្លាប់របស់សហគមន៍ (BCC) និងការតាមដានគម្រោង (CLTS) នៅសាលាស្រុកព្រៃឈរ ។
- ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព (គ.អ.ភ.) បានចំនួន ០៧វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន ២៤៥នាក់ (ស្រី ៨២នាក់) មកពីឃុំត្រពាំងព្រះ ឃុំមៀន ឃុំក្បួង ស្រុកព្រៃឈរ ។
- ថ្ងៃទី ២៧-២៨ ខែមីនា ឆ្នាំ២០១៤ ចុះបណ្តុះបណ្តាលដល់គ្រូ កសិករ និងអ្នកស្ម័គ្រចិត្តថែទាំសុខភាពភូមិ នៅស្រុកមេមត់ ។
- ថ្ងៃទី ២២-២៣ ខែមេសា ឆ្នាំ២០១៤ ចុះវាយតម្លៃ និងត្រួតពិនិត្យភូមិសម្រាប់ ODF នៅស្រុកព្រៃឈរ ។
- ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤ ចុះត្រួតពិនិត្យភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលជាមួយអង្គការ SNV នៅស្រុកកំពង់សៀម ។
- ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៤ ចូលរួមប្រជុំ ស្តីពីការផ្សព្វផ្សាយកម្មវិធីកំណែទម្រង់រដ្ឋបាល ។
- ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៤ ចូលរួមវេទិការសាធារណៈនៅស្រុកស្ទឹងត្រង់ ។
- ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៤ ចុះបំផុសអនាម័យជាមួយអង្គការ EMW នៅស្រុកចំការលើ ។
- ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៤ ចូលរួមប្រជុំពិភាក្សាពីការផ្គត់ផ្គង់អនាម័យជាមួយអង្គការ Water-Sad និងក្រសួងអភិវឌ្ឍន៍ជនបទនៅមន្ទីរអភិវឌ្ឍន៍ជនបទ ។
- ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៤ ចូលរួមសិក្ខាសាលាស្តីពីការពិភាក្សាស្រាវជ្រាវស្ថានភាពទឹកស្អាត និងអនាម័យក្នុងតំបន់រងការប៉ះពាល់ដោយសារធាតុអាសេនិច ជាមួយអង្គការយូនីសេស និងអង្គការទឹកភ្លៀងកម្ពុជា នៅសណ្ឋាគារលាភវីរៈសារ ។
- ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៤ ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្រុក នៅមន្ទីរអភិវឌ្ឍន៍ជនបទ ។
- ចូលរួមសម្របសម្រួលគ្រូបង្គោលថ្នាក់ស្រុក បាន ០២វគ្គ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ចុះត្រួតពិនិត្យ និងជំរុញអោយអ្នកស្ម័គ្រចិត្តភូមិសាងសង់បង្គន់តាមផ្ទះបាន ០៣លើក នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

- ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៤ ចូលរួមប្រជុំស្តីពីរបៀបរបបការងារក្នុងមន្ទីរ ។
- ចូលរួមបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលភូមិ និងអ្នកទទួលផលបាន ០៤វគ្គ នៅស្រុកព្រៃឈរ ។
- ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៤ ប្រជុំបូកសរុបការងារ នៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៤ ចូលរួមតាមដាន និងត្រួតពិនិត្យសុខភាពអនាម័យតាមសាលារៀន នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៤ ចូលរួមសិក្ខាសាលា ស្តីពីការត្រួតពិនិត្យសមិទ្ធផលគម្រោងពាក់កណ្តាលអាណត្តិ និងវិធានការចំពោះមុខ នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ។
- ថ្ងៃទី ២៩-៣១ ខែកក្កដា ឆ្នាំ២០១៤ ចូលរួមវគ្គបណ្តុះបណ្តាលបំប៉នគ្រូបង្គោល ស្តីពីការលើកកម្ពស់អនាម័យជនបទ និងត្រៀមបង្ការគ្រោះទឹកជំនន់នៅសណ្ឋាគារពន្លឺថ្មី ខេត្តកំពង់ធំ ។
- ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤ ចូលរួមប្រជុំបូកសរុបការងាររយៈពេល ០១ឆ្នាំ (ងូតទឹក-ដុសក្អែល-ឆ្នុះកញ្ចក់) នៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម ។
- ចូលរួមប្រជុំបូកសរុបការងារ ស្តីពីសុខភាពអនាម័យប្រចាំត្រីមាសទី២ បាន ២លើក នៅស្រុកស្ទឹងត្រង់ និងស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៣-១៤ ខែសីហា ឆ្នាំ២០១៤ ចូលរួមសិក្ខាសាលា ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅសណ្ឋាគារហ៊ារប៊ុនី ខេត្តក្រចេះ ។
- ថ្ងៃទី ១៣-១៥ ខែសីហា ឆ្នាំ២០១៤ ចុះផ្សព្វផ្សាយជ្រើសរើសសិស្សសម្រាប់បណ្តុះបណ្តាលមុខវិជ្ជាជីវៈ ក្នុងមណ្ឌលនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។
- ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៤ ផ្សព្វផ្សាយអនាម័យនៅស្រុកព្រៃឈរ ។

**៥- ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

1. **គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ**
   - ស្រុកចំនួន ០៧ស្រុក ឃុំចំនួន ២៣ឃុំ ភូមិចំនួន ៦៥ភូមិ ។
   - អតិថិជនសរុបចំនួន ១,០៤៦នាក់ ស្រីចំនួន ៨៣៥នាក់ ។
   - ក្រុមចំនួន ៦៤៣ក្រុម
   - ប្រាក់ដើមឱ្យខ្ចីចំនួន ១,៩៩៧,៨០០,០០០រៀល
   - ប្រាក់ដើមសងចំនួន ២,៥០៤,៣៦៤,៨០០រៀល
   - ប្រាក់ការសងចំនួន ៣៨២,៥៤៩,៤០០រៀល
   - ប្រាក់ដើមនៅជំពាក់ចំនួន ១,៧៩៤,៣០៨,៤០០រៀល
2. **គម្រោងឥណទានកូវ៉ៃ**
   - ស្រុកចំនួន ០៣ស្រុក ឃុំចំនួន ០៣ឃុំ ភូមិចំនួន ០៩ភូមិ ។
   - អតិថិជនសរុបចំនួន ៣០៤នាក់ ស្រីចំនួន ២៤៨នាក់ ។
   - ក្រុមចំនួន ១៣៨ក្រុម
   - ប្រាក់ដើមឱ្យខ្ចីចំនួន ៣៨៥,៣០០,០០០រៀល
   - ប្រាក់ដើមសងចំនួន ៥០៨,២៧៩,០០០រៀល
   - ប្រាក់ការសងចំនួន ៩២,៤៧៨,២០០រៀល

- ប្រាក់ដើមនៅជំពាក់ចំនួន ៤១៤,១៦៩,០០០រៀល

**៦- ការងារអភិវឌ្ឍន៍បណ្តុះបណ្តាល និងស្រាវជ្រាវ**

ដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបង្កើនជំនាញជូនដល់ប្រជាពលរដ្ឋក្រីក្រ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានចាប់ផ្តើមបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវជំនាញមូលដ្ឋានសំដៅឱ្យយុវជន យុវនារីក្រីក្រ កំព្រា ដែលមិនអាចមានលទ្ធភាពបន្តការសិក្សាទៅមុខទៀតដើម្បីឱ្យពួកគេមានជំនាញមួយពិតប្រាកដ ។ ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន បានធ្វើការផ្សព្វផ្សាយទៅដល់ភូមិ-ឃុំ តាមរយៈមន្ត្រីការិយាល័យស្រុក-ក្រុងទាំង ១០ស្រុក ខេត្តកំពង់ចាម និងបានផ្សព្វផ្សាយតាមវិទ្យុខេត្ត ដើម្បីជ្រើសរើសសិស្សចូលរៀនតាមមុខជំនាញ ។

❖ ការងារបណ្តុះបណ្តាលក្នុងមជ្ឈមណ្ឌល

+ ក្នុងវគ្គទី១

- ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៤ បានបើកវគ្គបណ្តុះបណ្តាលមុខជំនាញជួលជុលម៉ូតូ មានសិក្ខាកាមចូលរៀនចំនួន ១៥នាក់ ខាងបុរស ។
- ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៤ បានបើកវគ្គបណ្តុះបណ្តាលមុខជំនាញជួសជុលទូរស័ព្ទមានសិក្ខាកាមចូលរៀនចំនួន ១២នាក់ ខាងបុរស ។
- ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៤ បានបើកវគ្គបណ្តុះបណ្តាលជំនាញកែសម្ផស្សមានសិក្ខាកាមចូលរៀនចំនួន ១៥នាក់ ខាងនារី ។
- សរុបវគ្គទី១ មានចំនួនសិក្ខាកាម ៤២នាក់/ស្រី ១៥នាក់ ។

❖ ការងារបណ្តុះបណ្តាលនៅសហគមន៍

- ថ្ងៃទី ១២-១៣ ខែកក្កដា ឆ្នាំ២០១៤ និងថ្ងៃទី ១៨-២០ ខែកក្កដា ឆ្នាំ២០១៤ បើកវគ្គបណ្តុះបណ្តាលមុខជំនាញចិញ្ចឹមមាន់ និងដំណាំស្រូវមានអ្នកចូលរួមចំនួន ៣១នាក់ មានស្រី ០៣នាក់ ស្ថិតនៅភូមិដូង ឃុំសូទិព ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៩-២០ ខែកក្កដា ឆ្នាំ២០១៤ និងថ្ងៃទី ២៥-២៧ ខែកក្កដា ឆ្នាំ២០១៤ បើកវគ្គបណ្តុះបណ្តាលមុខជំនាញចិញ្ចឹមមាន់ និងដំណាំស្រូវមានអ្នកចូលរួមចំនួន ៣២នាក់/ស្រី ០៣នាក់ ។

❖ មន្ត្រីរាជការដែលកំពុងសហការជាមួយអង្គការអន្តរជាតិ និងអង្គការជាតិ

- អង្គការភ្លែន (PLAN) ០៥នាក់
- គម្រោងឥណទាន ក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ១៥នាក់
- អង្គការ ADB ០៦នាក់
- អង្គការយូនីសេហ្វ (UNICEF) ០៥នាក់
- កម្មវិធី RIP ០៤នាក់

❖ ការងារសហការជាមួយអង្គការ NGOs

❖ គម្រោងឧបត្ថម្ភស្បៀងបន្ទាន់

- ថ្ងៃទី ០៨-១៨ ខែកក្កដា ឆ្នាំ ២០១៤ មន្ត្រី ២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី អនាម័យដឹកនាំដោយសហគមន៍ឃុំគោលដៅចំនួន ០៨ របស់គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងហិរញ្ញប្បទានបន្ថែមខេត្តកំពង់ចាម។
- ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៤ ចូលសិក្ខាសាលាពិគ្រោះយោបល់ ស្តីអំពីការប្រែប្រួលអាកាសធាតុ និងការប្រកបរបរចិញ្ចឹមជីវិត ។

- ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៤ សិក្ខាសាលាស្តីពី ការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ក្រោមហិរញ្ញប្បទានបន្ថែមពាក់កណ្តាលអណត្តិ ។
- ថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១៤ សិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ២០១៤-២០១៨ ក្រោមអធិបតីភាពសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី) រាជធានីភ្នំពេញ( ។

❖ <u>ការងារអង្គការយូនីសេហ្វ</u>

- ថ្ងៃទី ២១-២២ ខែកក្កដា ឆ្នាំ២០១៤ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី អភិក្រមប្រកបដោយសុខុមដុមនីយកម្មក្នុងការផ្ទេរថវិកាដល់ដៃគូរអភិវឌ្ឍន៍គម្រោងនីតិវិធីហិរញ្ញវត្ថុ នីតិវិធីលទ្ធកម្ម និងវិធីសាស្ត្រក្នុងការសរសេររបាយការណ៍នៅខេត្តព្រះសីហនុ ដែលមានមន្ត្រីមន្ទីរទៅចូលរួមចំនួន ០២រូប ។
- សម្របសម្រួលអោយមានការប្រជុំផ្សព្វផ្សាយចំនួន ៣៦ដង ចុះតាមខ្នងផ្ទះបានចំនួន ១៣៣០ខ្នងផ្ទះ និងរកការបញ្ជាទិញបានប្រហែលចំនួន ៣០០បង្គន់ និងមានការដឹកចេញតាមរយៈការផ្សព្វផ្សាយបានចំនួន ២៧៥បង្គន់ ប្រចាំខែសីហា ឆ្នាំ ២០១៤ ។
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យគុណភាពទឹករយៈពេល ០៣ថ្ងៃ ប្រជុំផ្សព្វផ្សាយពីកម្មវិធីបន្សុទ្ធទឹក និងទុកដាក់ទឹកអោយមានសុវត្ថិភាពតាមគ្រួសារ នៅស្រុកកោះសូទិន ។
- បានធ្វើការបណ្តុះបណ្តាលដល់ប្រធានក្រុមប្រើប្រាស់ទឹក និងជនបង្គោលឃុំនៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ។
- ថ្ងៃទី ០៥-០៧ ខែសីហា ឆ្នាំ២០១៤ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្តីពី ការអនុវត្តកម្មវិធីសហគមន៍ដឹកនាំអនុវត្តន៍អនាម័យ ដែលមានអង្គការ Plan និងអង្គការ Unicef ជាអ្នករៀបចំកម្មវិធី។
- ថ្ងៃទី ១១-១២ ខែកញ្ញា ឆ្នាំ២០១៤ មន្ត្រីការិយាល័យសុខភាពនៃមន្ទីរអភិវឌ្ឍន៍ជនបទ ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀននៅខេត្តកំពត ។

❖ <u>ការងារយេនឌ័រ</u>

- ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៤ លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី២៩ របស់គណៈកម្មាធិការសម្របសម្រួលគម្រោងសាលល្បែង នៅមន្ទីរកិច្ចនារីខេត្ត ។
- ថ្ងៃទី ១០-១១ ខែមិថុនា ឆ្នាំ ២០១៤ លោកប្រធានមន្ទីរ និងលោកស្រី ប៉ាន ផល្លីន ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំអនុសាសន៍សម្រាប់គោលនយោបាយនៅរាជធានីភ្នំពេញ ។
- ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១៤ លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី២៩ របស់គណៈកម្មាធិការសម្របសម្រួលគម្រោងសាលល្បែងនៅមន្ទីរកិច្ចនារីខេត្ត ។
- ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៤ លោកប្រធានមន្ទីរ ចូលរួមប្រជុំស្តីពីការផ្សព្វផ្សាយការងាររៀបចំផលិតផលក្នុងស្រុកសរុប (GDP) ខេត្តកំពង់ចាម ។

**៧ -** <u>ការិយាល័យជនជាតិដើមភាគតិច</u> (គ្មានសកម្មភាព)

## IV. ទិសដៅផែនការឆ្នាំ២០១៤

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិអង្គការសហគមន៍នានាឱ្យមានភាពកាន់តែប្រសើរឡើងដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាពល

រដ្ឋមានលក្ខណសមស្របពីមួយថ្ងៃទៅមួយថ្ងៃ និងស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

V. **បញ្ហាប្រឈម**

ស្របតាមសម្ទិផលដែលទទួលបានពីអនុវត្តន៍ការងារក្នុងឆ្នាំកន្លងមក មន្ទីរបានកត់សម្គាល់ឃើញថាៈ មានការប្រឈមមួយចំនួននៅពេលចុះអនុវត្តន៍ការងារដូចជា ÷

- ការពង្រឹងធនធានមនុស្សដល់មន្ត្រីមន្ទីរនូវមានកម្រិត ព្រោះការបណ្តុះបណ្តាលជំនាញបច្ចេកទេស នៅពុំទាន់បានសមស្របតាមផ្លូវការ ។
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត ក្នុងការថែទាំសមិទ្ធិផលដែលបានផ្តល់ការយល់ដឹងរបស់ប្រជាពលរដ្ឋលើការថែទាំសុខភាព និងអនាម័យនៅមានកង្វះខាតច្រើន ព្រោះការអប់រំផ្សព្វផ្សាយនៅពុំទាន់បានទូលំទូលាយ ជាហេតុធ្វើអោយការផ្លាស់ប្តូរទម្លាប់ របស់សហគមន៍នៅមានភាពយឺតយ៉ាវ ។

VI. **សន្និដ្ឋាន**

យោងតាមរបាយការណ៍អនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍បានបង្ហាញឱ្យឃើញថាៈ ដើម្បីអនុវត្តន៍ផែនការអភិវឌ្ឍន៍ជនបទ បានសម្រេចលុះត្រាតែយើងបានអនុវត្តនូវសកម្មភាពដូចខាងក្រោម÷

- ធ្វើអោយមានសកម្មភាពឡើងវិញនូវគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ.) ដែលត្រូវបានចំណាត់ថ្នាក់ជាអាទិភាពនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជនបទ ។
- ការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា សំណង់ធារាសាស្ត្រផ្លូវជនបទ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ ដោយអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជនបទ របស់មន្ទីរបានបង្ហាញឱ្យឃើញថា ខេត្តកំពង់ចាម ទទួលបានការអភិវឌ្ឍន៍ដូចជា ស្ពាន និងផ្លូវលំជនបទខ្វាត់ខ្វែងសម្រាប់ប្រជាពលរដ្ឋធ្វើចរាចរណ៍ក្នុងការដឹកនាំកសិផលដែលជាកត្តា ធ្វើអោយប្រជាពលរដ្ឋកាន់តែជិតរវាងជនបទ និងទីប្រជុំជន ។ ធ្វើឱ្យប្រជាជនមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ ជាពិសេសធ្វើអោយយល់ដឹងពីសុខភាព និងអនាម័យតាមរយៈការអប់រំផ្សព្វផ្សាយ និងប្រើប្រាស់បង្គន់អនាម័យ ។

សរុបសេចក្តីមក យើងឃើញថា ការអនុវត្តន៍គោលនយោបាយ និងផែនការអភិវឌ្ឍន៍ជនបទ បានចូលរួមអនុវត្តន៍ឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ អាណត្តិទី៥ និងគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លៃវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើងសំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ធ្វើឱ្យប្រជាពលរដ្ឋមានល័ក្ខខ័ណ្ឌល្អប្រសើក្នុងជីវភាពរស់នៅ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។

**ប្រធានមន្ទីរ**